# ព័ត៌មានស្តីពីការចាក់វ៉ាក់សាំងកូវីដ-១៩ លើកទី៣(ដូសជំរុញ) សម្រាប់ជនបរទេសដែលរស់នៅក្នុងប្រទេសកូរ៉េ(អាយុលើសពី ១៨ឆ្នាំ)

ការចាក់វ៉ាក់សាំង គឺថយចុះប្រសិទ្ធភាពនៅពេលដែលពេលវេលាកន្លងផុតទៅ ហើយហានិភ័យនៃការឆ្លងកើនឡើង។ កូវីដ-១៩ ប្រសិនបើ បានបញ្ចប់ការចាក់វ៉ាក់សាំងលើកទី៣(ដូសជំរុញ) គឺមានប្រសិទ្ធភាពខ្ពស់ក្នុងការការពារការឆ្លងមេរោគ និងជំងឺធ្ងន់ធ្ងរ ជាងការចាក់វ៉ាក់សាំង ជាមូលដ្ឋានតែប៉ុណ្ណោះ។
ថ្មីៗនេះ ក្នុងចំណោមអ្នកឆ្លងជំងឺកូវីដ១៩ អត្រានៃការកើតឡើងលើជនបរទេស គឺមានអត្រាខ្ពស់ ប៉ុន្តែផ្ទុយទៅវិញអត្រាចាក់វ៉ាក់សាំងលើកទី៣សម្រាប់ជនបរទេស គឺទាបជាងជនជាតិកូរ៉េ ដូច្នេះដើម្បីជីវិតប្រកបដោយសុវត្ថិភាពនៅប្រទេសកូរ៉េ ដាច់ខាតត្រូវតែចាក់វ៉ាក់សាំងលើកទី៣។
ជនបរទេសដែលមានអាយុលើសពី១៨ឆ្នាំ ដែលបានបញ្ចប់ការចាក់វ៉ាក់សាំងជាមូលដ្ឋាននៅក្នុងប្រទេសកូរ៉េ ឬនៅបរទេស គឺអាចទទួលការ ចាក់វ៉ាក់សាំងលើកទី៣(ដូសជំរុញ) ដោយមិនគិតថ្លៃ។

○ ពេលវេលានៃការចាក់វ៉ាក់សាំង

- ប្រសិនបើកន្លងផុត ៣ខែ(៩០ថ្ងៃ) បន្ទាប់ពីបានបញ្ចប់ការចាក់វ៉ាក់សាំងមូលដ្ឋាន អ្នកអាចទទួលការចាក់វ៉ាក់សាំងលើកទី៣បាន។ សម្រាប់អ្នកដែលបានចាក់វ៉ាក់សាំងយ៉ាន់សេន គឺអាចចាក់ដូសទីពីរ(ដូសជំរុញ) ក្រោយរយៈពេល ២ខែ(៦០ថ្ងៃ) បានកន្លងផុតទៅ។

* ការចាក់វ៉ាក់សាំងមូលដ្ឋាន: សម្រាប់វ៉ាក់សាំងហ្វាយសឺរ·ម៉ូតូណា·អាស្ត្រាហ្សឺនេកា គឺត្រូវចាក់២ដង, វ៉ាក់សាំងយ៉ាន់សេន គឺចាក់១ដង

- ប្រសិនបើមិនបានចាក់វ៉ាក់សាំងលើកទី៣ ក្នុងរយៈពេល៦ខែ បន្ទាប់ពីការបញ្ចប់ការចាក់វ៉ាក់សាំងមូលដ្ឋាននោះ ប្រសិទ្ធភាពនៃប័ណ្ណឆ្លង កាត់បញ្ចប់ការចាក់វ៉ាក់សាំងកូវីដ១៩ ត្រូវបានបាត់បង់ ហើយប្រសិទ្ធភាពត្រូវបានទទួលស្គាល់ភ្លាមៗនៅពេលទទួលចាក់វ៉ាក់សាំងលើក ទី៣។

○ ប្រភេទ វ៉ាក់សាំង និងទីកន្លែងសម្រាប់ចាក់វ៉ាក់សាំង

- បច្ចុប្បន្ននេះ ការចាក់វ៉ាក់សាំងលើកទី៣ គឺកំពុងត្រូវបានអនុវត្ត ដោយចាក់ជាមួយនឹងវ៉ាក់សាំង mRNA (ហ្វាយសឺរ, ម៉ូតូណា)។ ប៉ុន្តែក្នុង ចំណោមអ្នកដែលបានចាក់វ៉ាក់សាំងយ៉ាន់សេន ករណីដែលអ្នកចង់ចាក់វ៉ាក់សាំងលើកទី២(ដូសជំរុញ)
  ជាវ៉ាក់សាំងយ៉ាន់សេនសូមសាក សួរទៅកាន់មណ្ឌលសុខភាពសាធារណៈ ដែលនៅជិតបំផុត។
- មិនថាឡើយអ្នកមានធានារ៉ាប់រងសុខភាព ឬអត់នោះទេ អ្នកអាចទទួលចាក់វ៉ាក់សាំងនៅស្ថាប័នវេជ្ជសាស្ត្រ ឬមណ្ឌលសុខភាពសាធារ ណៈ ដែលផ្តល់វ៉ាក់សាំងការពារជំងឺកូវីដ-១៩។

○ វិធីសាស្រ្តចុះឈ្មោះ

① ជនបរទេសដែលបានបញ្ចប់ការចាក់វ៉ាក់សាំងមូលដ្ឋាននៅប្រទេសកូរ៉េ

១) ជនដែលបានចុះឈ្មោះជាជនបរទេស៖ គឺអាចកក់បានតាមរយៈអនឡាញ ឬទូរស័ព្ទ ដូចគ្នានឹងការចាក់វ៉ាក់សាំងមូលដ្ឋានផងដែរ។

* ការកក់តាមរយៈអនឡាញ : ចូលប្រើប្រព័ន្ធកក់ទុកមុននៃការចាក់វ៉ាក់សាំងកូវីដ១៩(https://ncvr.kdca.go.kr) ហើយធ្វើការកក់ទុក បន្ទាប់ពីផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អ្នក។

** ការកក់ទុកតាមទូរស័ព្ទ : មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺកូរ៉េ(☏១៣៣៩) ឬលេខទូរស័ព្ទសម្រាប់ការប្រឹក្សាការកក់ទុកដោយរដ្ឋា ភិបាលក្នុងតំបន់ផ្សេងៗ(ចូលទៅកាន់ https://ncv.kdca.go.kr → ពិនិត្យមើល'ស្ថានភាពប្រតិបត្តិការកក់ទូរស័ព្ទនៃការចាក់វ៉ាក់សាំង កូវីដ១៩' )

២) ជនដែលមិនបានចុះឈ្មោះជាជនបរទេស(រួមទាំង ជនបរទេសខុសច្បាប់) : អ្នកអាចធ្វើការកក់ទុកតាមទូរស័ព្ទ ឬទៅកក់ផ្ទាល់នៅស្ថា ប័នសម្រាប់ចាក់វ៉ាក់សាំង(ស្ថាប័នវេជ្ជសាស្រ្ត ឬមណ្ឌលសុខភាពសាធារណៈ) ដោយប្រើលេខគ្រប់គ្រងបណ្តោះអាសន្នដែលចេញដោយ មណ្ឌលសុខភាពសាធារណៈ នៅពេលចាក់វ៉ាក់សាំងមូលដ្ឋាន។

② ជនបរទេសដែលបានចាក់វ៉ាក់សាំងមូលដ្ឋាននៅបរទេស(រួមទាំងជនបរទេសដែលស្នាក់នៅរយៈពេលខ្លី ក្រោម៩០ថ្ងៃ)

- អ្នកអាចធ្វើការកក់ទុកដោយទៅមណ្ឌលសុខភាពសាធារណៈផ្ទាល់ ដែលនៅជិត ដោយភ្ជាប់ជាមួយអត្តសញ្ញាណប័ណ្ណរបស់អ្នក

បន្ទាប់ពី ទទួលបានលេខគ្រប់គ្រងបណ្តោះអាសន្ន និងចុះឈ្មោះប្រវត្តិនៃការចាក់វ៉ាក់សាំងនៅបរទេសរបស់អ្នកហើយ បន្ទាប់មកធ្វើការកក់ទុក តាមទូរស័ព្ទ ឬទៅកក់ផ្ទាល់នៅស្ថាប័នសម្រាប់ចាក់វ៉ាក់សាំង(ស្ថាប័នវេជ្ជសាស្ត្រ ឬមណ្ឌលសុខភាពសាធារណៈ)។

* ជនដែលបានចុះឈ្មោះជាជនបរទេស គឺមិនចាំបាច់ចេញលេខគ្រប់គ្រងបណ្តោះអាសន្នទេ។

※ សេចក្តីយោង

- ព័ត៌មានដែលពាក់ព័ន្ធនឹងអត្តសញ្ញាណ គឺត្រូវបានប្រើសម្រាប់គោលបំណងចាក់វ៉ាក់សាំងតែប៉ុណ្ណោះ និងយោងតាមប្រព័ន្ធលើកលែង កាតព្វកិច្ចជូនដំណឹង គឺនឹងមិនត្រូវបានជូនដំណឹងអំពីស្នាក់នៅដោយខុសច្បាប់ផ្សេងៗ ទៅការិយាល័យអន្តោប្រវេសន៍·ជនបរទេសទេ។
- សម្រាប់ព័ត៌មានបន្ថែម សូមមើលនៅលើគេហទំព័ររបស់មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺកូរ៉េ(KCDC) សម្រាប់ការចាក់វ៉ាក់សាំង កូវីដ១៩(https://ncv.kdca.go.kr)។

ក្រសួងកិច្ចការនារី និងគ្រួសារ មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺកូរ៉េ

< បកប្រែដោយមជ្ឈមណ្ឌលប្រឹក្សាតាមទូរស័ព្ទដានូរី ១៥៧៧-១៣៦៦>